# LYNN PUBLIC SCHOOLS

**James Leo McGuinness Administration Building – 100 Bennett Street, Lynn, MA 01905**
**Tel. (781) 477-7220 ~ Fax. (781) 477-7312**

**Patrick A. Tutwiler, Ph.D.**
**Superintendent of Schools**

ថ្ងៃទី ១០ ខែកុម្ភៈឆ្នាំ ២០២០

គោរពចំពោះក្រុមគ្រួសារទាំងឡាយ៖

ជារៀងរាល់ឆ្នាំ សាលារៀនសាធារណៈ និងមណ្ឌលសាលារៀននីមួយៗក្នុងរដ្ឋម៉ាស្សាឈូសេតទទួលបានប័ណ្ណរបាយការណ៍។ គឺដូចទៅនឹងប័ណ្ណរបាយការណ៍របស់កូនអ្នកបង្ហាញថាតើពួកគេធ្វើបានយ៉ាងណានៅក្នុងមុខវិជ្ជាខុសផ្សេងៗគ្នាដែរ ប័ណ្ណរបាយការណ៍របស់សាលារៀនត្រូវបានតាក់តែងរចនាឡើងដើម្បីបង្ហាញក្រុមគ្រួសារថាតើ សាលារៀនរបស់យើងធ្វើបានយ៉ាងដូចម្តេចនៅក្នុងវិស័យផ្សេងៗខុសៗគ្នា។ តំណភ្ជាប់ទៅនឹងប័ណ្ណរបាយការណ៍របស់ សាលារៀនយើងមាននៅ reportcards.doe.mass.edu។

ប័ណ្ណរបាយការណ៍រួមបញ្ចូលនូវរង្វាស់ជាច្រើននៃដំណើរការអនុវត្តបានរបស់សាលារៀន – គឺលើសពីគ្រាន់តែជាពិន្ទុ MCAS ទៅទៀត។ វាតំណាងនូវវិធីថ្មីនៃការពិនិត្យមើលទៅលើដំណើរការអនុវត្តបានរបស់សាលារៀនដោយផ្តល់ព័ត៌មានស្តីអំពីសមិទ្ធផលសម្រេចបានរបស់សិស្ស គុណវឌ្ឍិរបស់គ្រូបង្រៀន ឱកាសសិក្សារៀនសូត្ររបស់សិស្សានុសិស្ស និងអ្វីច្រើនថែមទៀត។

ប័ណ្ណរបាយការណ៍ត្រូវបានតាក់តែងរចនាឡើងដើម្បីជាឧបករណ៍មានប្រយោជន៍សម្រាប់គ្រប់គ្នាដែលត្រូវបានផ្សារភ្ជាប់ទាក់ទងនឹងសាលារៀនយើង។ ក្រុមគ្រួសារសិស្សអាចប្រើប្រាស់ព័ត៌មាននោះដើម្បីមានការសន្ទនាដ៏មានន័យជាមួយយើងខ្ញុំអំពីអ្វីដែលសាលារៀនកំពុងធ្វើបានល្អ និងកន្លែងដែលមានកន្លែងសម្រាប់ធ្វើការកែលម្អឲ្យបានប្រសើរឡើង។ សហគមន៍ និងអ្នកដឹកនាំការអប់រំអាចប្រើប្រាស់ព័ត៌មាននោះដើម្បីយល់បានកាន់តែប្រសើរថាតើត្រូវជ្រោមជ្រែងសិស្សានុសិស្ស និងសាលារៀនយើងខ្ញុំដោយរបៀបណា។ យើងខ្ញុំសូមលើកទឹកចិត្តជម្រុញលោកអ្នកឲ្យចូលពាក់ព័ន្ធនៅក្នុងការជួយយើងខ្ញុំឲ្យធ្វើការកែលម្អសាលារៀនយើងខ្ញុំឲ្យកាន់តែប្រសើរឡើង។ យើងខ្ញុំឃើញឪពុកម្តាយថាជាដៃគូដ៏សំខាន់នៅក្នុងភាពជោគជ័យនៃសិស្សានុសិស្ស និងសាលារៀនយើង ហើយយើងមានសេចក្តីដឹងគុណចំពោះការជួយជ្រោមជ្រែងជាប់បន្តរបស់អ្នក។
ចុងបញ្ចប់នេះ ប្រសិនបើកូនអ្នកមករៀននៅសាលារៀនដែលទទួលបានមូលនិធិសហព័ន្ធនៅក្នុងចំណងជើង I អ្នកក៏អាចមានសិទ្ធិផងដែរក្នុងការស់ណូមពរព័ត៌មានដូចតទៅនេះអំពីគុណវឌ្ឍិនៃគ្រូបង្រៀនរបស់ថ្នាក់រៀនកូនអ្នកបាន៖

- ថាតើគ្រូបង្រៀនកូនអ្នកត្រូវបានផ្តល់អាជ្ញាប័ណ្ណនៅក្នុងកម្រិតថ្នាក់រៀន និងផ្នែកមុខវិជ្ជាដែលពួកគេបង្រៀនដែរឬទេ
- ថាតើគ្រូបង្រៀនកូនអ្នកកំពុងបង្រៀននៅក្រោមអាជ្ញាប័ណ្ណអាសន្នបន្ទាន់ ឬលើកលែងដែរឬទេ
- កម្រិតសញ្ញាប័ត្រមហាវិទ្យាល័យ និងមុខវិជ្ជាជំនាញរបស់គ្រូបង្រៀនកូនរបស់អ្នក និង
- ថាតើកូនអ្នកត្រូវបានផ្តល់នូវសេវាកម្មដោយអ្នកជំនួយអមវិជ្ជាជីវៈដែរឬទេ ហើយ ប្រសិនបើដូចនោះមែន គុណវឌ្ឍិរបស់ពួកគេយ៉ាងម៉េចខ្លះ

ប្រសិនបើអ្នកមានសំណួរអំពីប័ណ្ណរបាយការណ៍សាលារៀនយើងខ្ញុំ ចង់មានការពាក់ព័ន្ធនៅក្នុងសកម្មភាពកែលម្អសាលារៀនឲ្យប្រសើរឡើង ឬចង់ស្នើសុំព័ត៌មានអំពីគុណវឌ្ឍិនៃគ្រូបង្រៀនថ្នាក់រៀនរបស់កូនអ្នក សូមទាក់ទងសាលារបស់អ្នក ។ ដើម្បីមើលប័ណ្ណរបាយការណ៍មណ្ឌលសាលារៀនយើង ឬដើម្បីស្វែងរកមើលប័ណ្ណរបាយការណ៍សាលារៀនដទៃផ្សេងទៀតនោះ សូមចូលមើលនៅក្នុងគេហទំព័រ reportcards.doe.mass.edu។

ដោយក្តីរាប់អានដ៏ស្មោះស្ម័គ្រ

Patrick A. Tutwiler, Ph.D.
យកមណលសិកធិរ